## ស្បៀងអាហារ

- វិបត្តិជំងឺកូវីដ-១៩ កំពុងធ្វើឱ្យអសន្តិសុខស្បៀងកាន់តែធ្ងន់ធ្ងរ ដោយសារតែការកម្រិតលើសិទ្ធិសេរីភាពក្នុងការដើរហើរ និងខ្វះខាតឧបករណ៍ការពារប៉ះពាល់ដល់កម្មករកសិកម្ម ដែលភាគច្រើនជាទេសន្តរប្រវេសន៍ក្នុងបរិបទខ្លះ។ វិធានការ ដើម្បីធានាការចល័ត និងលក្ខខណ្ឌការងារប្រកបដោយសុវត្ថិភាពរបស់កម្មករកសិកម្ម គួរតែដាក់ចេញជាបន្ទាន់ ដើម្បីធានាផលិតកម្មស្បៀង ក៏ដូចជា អភិក្រមដែលបានកំណត់គោលដៅ ដូចជា ការគាំទ្រផ្នែកហិរញ្ញវត្ថុ និងការទទួលបានឥណទាន ទីផ្សារ និងផលិតផលកសិកម្ម មានដូចជា គ្រាប់ពូជ សម្រាប់កសិករខ្នាតតូច ជាពិសេស ស្ត្រី។
- វិធានការបន្ទាន់គឺចាំបាច់ ដើម្បីដោះស្រាយអសន្តិសុខស្បៀង សម្រាប់ប្រជាជនក្រីក្របំផុត និងក្រុមមនុស្សដែលបាត់បង់ឱកាសបំផុត។ វិធានការដែលសំដៅផ្តល់ការគាំទ្រជាបន្ទាន់ ដើម្បីបំពេញតម្រូវការរបស់ប្រជាជនដែលត្រូវអាហារូបត្ថម្ភ គួរតែត្រូវបានបង្កើតឱ្យមាន ដែលរួមមានការផ្តល់ជំនួយស្បៀង និងអាហារូបត្ថម្ភ។